Manulife

# ជំងឺធ្ងន់ធ្ងរកម្រិតដំបូង

ជំងឺធ្ងន់ធ្ងរកម្រិតដំបូងដែលត្រូវបានធានាក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ សំដៅដល់ ជំងឺ ឬស្ថានភាពណាមួយ ដែលបានកំណត់និយមន័យ ដូចខាងក្រោម៖

| តារាងនៃជំងឺធ្ងន់ធ្ងរកម្រិតដំបូង | | | |
|---|---|---|---|
| **លេខ** | **ផ្នែកសរីរាង្គ** | **ជំងឺ ឬស្ថានភាពជំងឺធ្ងន់ធ្ងរ** | **និយមន័យ** |
| 1 | មហារីក | ជំងឺមហារីកកម្រិតដំបូង (Early Cancer) | ជំងឺមហារីកកម្រិតដំបូង (Early Cancer) – ជំងឺមហារីកកម្រិតដំបូង គឺជាដុំមហារីកដែលមិនទាន់រីករាលដាលដល់កោសិកានៃសរីរាង្គផ្សេងៗទៀត។<br>ដុំមហារីកដែលមិនទាន់រីករាលដាល (Carcinoma in situ) គឺជាការរីកលូតលាស់របស់កោសិកាមហារីកដែលមិនទាន់រីករាល ដាល ឬក៏ទៅបំផ្លាញកោសិកាដែលនៅជុំវិញ។ ការរីករាលដាល (Invasion) មានន័យថាជាការជ្រៀតចូលនៃកោសិកាមហារីក និង/ឬ ការបំផ្លាញសកម្មនៃកោសិកាធម្មតារហូតដល់ភ្នាសគ្រឹះនៃជាលិកា។ រោគវិនិច្ឆ័យនៃដុំមហារីកដែលមិនទាន់រីករាលដាលត្រូវតែបានធ្វើឡើងដោយផ្អែកទៅលើលទ្ធផលនៃការវិភាគដុំសាច់។ ជាងនេះទៅទៀតរោគវិនិច្ឆ័យរបស់ដុំមហារីកដែលមិនទាន់រីករាលដាល ត្រូវតែបានធ្វើរោគវិនិច្ឆ័យជាវិជ្ជមានដោយផ្អែកទៅលើការពិនិត្យមីក្រូទស្សន៍នៃជាលិកា ហើយដែលបានផ្អែកទៅលើលទ្ធផលនៃការវិភាគដុំសាច់។<br>ការធ្វើរោគវិនិច្ឆ័យតាមសញ្ញាគ្លីនិកមិនមានលក្ខណៈសមស្របតាមបទដ្ឋាននេះទេ។<br><br>ករណីខាងក្រោមនេះនឹងពុំមានការធានាទេ៖<br>• កោសិកាមិនធម្មតានៅមាត់ស្បូន ដំណាក់កាលទី1 (CIN-1) ដំណាក់កាលទី2 (CIN-2) ដំណាក់កាលទី3 (CIN-3) និងកោសិកាមិនធម្មតាដែលរីកលូតលាស់តិចតួច មធ្យម ឬធ្ងន់ធ្ងរ នៅលើផ្ទៃខាងលើរបស់មាត់ស្បូន។<br>• ការរីកលូតលាស់ខុសធម្មតារបស់ក្រពេញប្រូស្តាត។<br>• ការរីកលូតលាស់ខុសធម្មតារបស់កោសិកានៅទ្វារមាស។<br>• ការរីកលូតលាស់ខុសធម្មតារបស់កោសិកាស្បែក។<br>• ដំបៅ ឬដុំសាច់ណាមួយដែលការវិភាគកោសិកាបញ្ជាក់ថាជាដុំសាច់ស្លូត ការវិវត្តន៍ខុសពីធម្មតារបស់កោសិកា ដុំដែលមិនទាន់ក្លាយជាមហារីកដុំដែលមិនប្រាកដថាជាមហារីក ឬដុំដែលសង្ស័យថាជាមហារីក។<br>• គ្រប់ដុំសាច់ទាំងអស់ដែលកើតមាននៅលើអ្នកផ្ទុកមេរោគហ៊ីវ។ |
| 2 | មហារីក | ជំងឺមហារីកក្រពេញប្រូស្តាតកម្រិតដំបូង (Early Prostate Cancer) | ដុំមហារីកក្រពេញប្រូស្តាតត្រូវបានពិពណ៌នាដោយចំណាត់ថ្នាក់ T1N0M0 (ចំណាត់ថ្នាក់របស់ដុំមហារីក TNM) ឬជំងឺមហារីកក្រពេញ |

Manulife

| | | | |
|---|---|---|---|
| | | | ប្រូស្តាត ត្រូវបានពិពណ៌នាដោយចំណាត់ថ្នាក់ផ្សេងៗទៀតដែលមានកម្រិតចំណាត់ថ្នាក់សមមូលគ្នា។ |
| 3 | មហារីក | ជំងឺមហារីកក្រពេញទីរ៉ូអ៊ីតកម្រិតដំបូង (Early Thyroid Cancer) | ជំងឺមហារីកក្រពេញទីរ៉ូអ៊ីតត្រូវបានពិពណ៌នាដោយចំណាត់ថ្នាក់ T1N0M0 (ចំណាត់ថ្នាក់របស់ដុំមហារីក TNM) ឬដុំកោសិការបស់ក្រពេញទីរ៉ូអ៊ីតដែលមានប្រវែងអង្កត់ផ្ចិតតិចជាង 1 សង់ទីម៉ែត្រ។ |
| 4 | មហារីក | ជំងឺមហារីកប្លោកនោមកម្រិតដំបូង (Early Bladder Cancer) | ជំងឺមហារីកប្លោកនោមត្រូវបានពិពណ៌នាដោយចំណាត់ថ្នាក់ T1N0M0 (ចំណាត់ថ្នាក់របស់ដុំមហារីក TNM) ឬដុំកោសិការបស់ប្លោកនោមដែលមានកម្រិត TaN0M0។ |
| 5 | មហារីក | ជំងឺមហារីកគ្រាប់ឈាមរ៉ាំរ៉ៃកម្រិតដំបូងដែលបណ្តាលមកពីការខូចខួរឆ្អឹង (Early Chronic Lymphocytic Leukemia) | ជំងឺមហារីកគ្រាប់ឈាមដែលបណ្តាលមកពីការខូចខួរឆ្អឹងនៅដំណាក់កាលទី 1 ឬទី 2 (RaiStage 1 or 2)។ សម្រាប់ដំណាក់កាល សូន្យ (Rai stage 0) ឬទាបជាងនេះ គឺមិនត្រូវបានទទួលការធានានោះទេ។ |
| 6 | បេះដូង | ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬការប្រើឧបករណ៍ជំនួយដល់ការកន្ត្រាក់សាច់ដុំបេះដូងជាអចិន្ត្រៃយ៍ (Insertion of a Permanent Cardiac Pacemaker or Defibrillator) | ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬការប្រើឧបករណ៍សម្រាប់ជំនួយដល់ការកន្ត្រាក់សាច់ដុំបេះដូង ដែលជាតម្រូវការបន្ទាប់ពីចង្វាក់បេះដូងដើរមិនទៀងទាត់យ៉ាងធ្ងន់ធ្ងរដែលមិនអាចព្យាបាលតាមវិធីផ្សេងៗទៀតបាន។ ការដាក់បញ្ចូលថ្មជំនួយបេះដូង ត្រូវបានណែនាំថាជាតម្រូវការចាំបាច់ដាច់ខាតដោយគ្រូពេទ្យឯកទេសដែលមានជំនាញពាក់ព័ន្ធ។<br><br>ថ្មជំនួយបេះដូង ឬឧបករណ៍សម្រាប់ជំនួយដល់ការកន្ត្រាក់សាច់ដុំបេះដូង ត្រូវបានណែនាំថាជាតម្រូវការចាំបាច់ដាច់ខាតដោយគ្រូពេទ្យឯកទេសបេះដូង។ |
| 7 | បេះដូង | ការវះកាត់ជួសជុលសរសៃឈាមបេះដូង (Coronary Angioplasty) | ដំណើរការនៃការវះកាត់ជួសជុលសរសៃឈាមដោយប្រើបាឡុង ឬបំពង់សរសៃឈាមដើម្បីកែតម្រូវនូវភាពចង្អៀតជាអប្បរមា 60% នៃសរសៃឈាមបេះដូងសំខាន់ៗមួយ ឬច្រើន ដូចដែលបានបង្ហាញដោយម៉ាស៊ីនឆ្លុះសរសៃឈាម។ ការធ្វើឲ្យសរសៃឈាមមានចលនាឡើងវិញត្រូវតែបានពិចារណាថាជាការចាំបាច់ខាងផ្នែកវេជ្ជសាស្ត្រដោយអ្នកជំនាញខាងជំងឺបេះដូង។<br><br>សរសៃឈាមបេះដូងដែលបានចែងនៅទីនេះ សំដៅទៅលើសរសៃឈាមចម្បងដែលនៅខាងឆ្វេងព័ទ្ធចុះមកក្រោមព័ទ្ធជារង្វង់ និងសរសៃឈាមបេះដូងដែលនៅខាងស្តាំ។<br><br>សូមគូសបញ្ជាក់ថាទម្រង់ការប្រមូលព័ត៌មាន ឬរោគវិនិច្ឆ័យពាក់ព័ន្ធនឹងបញ្ហាបេះដូង គឺមិនត្រូវបានទទួលការធានានោះទេ។ |
| 8 | បេះដូង | ការវះកាត់តិចតួចនៃសរសៃឈាមក្រហមធំ (Minimally Invasive Surgery to Aorta) | ការវះកាត់តិចតួចជាក់ស្តែងនៃសរសៃឈាមក្រហមធំ ឬបច្ចេកទេសព្យាបាលសរសៃឈាមក្រហមដើម្បីជួសជុល ឬកែសម្រួលការរីកប៉ោងការស្ទះ ឬការរហែកនៃសរសៃឈាមក្រហមធំ (Aorta) ដូចមានបញ្ជាក់ក្នុងលទ្ធផលនៃការធ្វើរោគវិនិច្ឆ័យច្បាស់លាស់ និងបញ្ជាក់ដោយគ្រូពេទ្យឯកទេស។<br><br>ក្នុងនិយមន័យនេះ សរសៃឈាមក្រហមធំ (Aorta) សំដៅទៅលើសរសៃឈាមក្រហមធំ (Aorta) ដែលភ្ជាប់ពីបេះដូងឆ្លងកាត់ទ្រូងទៅ |

| | | | |
|---|---|---|---|
| | | | ពោះ (thoracic and abdominal aorta) ដោយមិនរាប់បញ្ចូលនូវសរសៃមែកធាងសាខារបស់វាឡើយ។<br><br>សូមគូសបញ្ជាក់ថាទម្រង់ការប្រមូលព័ត៌មាននៃសរសៃឈាមក្រហមនឹងមិនត្រូវទទួលបានការធានានោះទេ។ |
| 9 | ខួរក្បាល | ការវះកាត់សរសៃឈាមខួរក្បាល ឬដុំសរសៃឈាមខួរក្បាលដែលមានភាពមិនប្រក្រតី (Cerebral Arteriovenous Malformation (AVM) / Cerebral Aneurysm Surgery) | ការព្យាបាលនេះ<br>• ការវះកាត់ជួសជុលសរសៃឈាមដែលរីកប៉ោងនៅក្នុងខួរក្បាល ឬការវះកាត់ចេញនូវភាពមិនប្រក្រតីនៃសរសៃឈាមខួរក្បាលតាមរយៈការចោះឆ្អឹងលលាដ៍ក្បាល ដែលត្រូវបានធ្វើឡើងដោយគ្រូពេទ្យផ្នែកវះកាត់ខួរក្បាល ឬ<br>• ទម្រង់ការព្យាបាលសរសៃឈាមក្នុងខួរក្បាលដោយអ្នកជំនាញខាងវិទ្យុសាស្ត្រ ដោយប្រើប្រាស់ឧបករណ៍ដែលជម្រុញឲ្យមានកំណកឈាមក្នុងសរសៃឈាមខួរក្បាល ឬដុំសរសៃឈាមខួរក្បាលដែលមិនប្រក្រតី។<br><br>សូមគូសបញ្ជាក់ថាទម្រង់ការនេះត្រូវបានណែនាំថាជាតម្រូវការចាំបាច់ដាច់ខាតដោយគ្រូពេទ្យឯកទេសដែលពាក់ព័ន្ធ។ |
| 10 | ថ្លើម | ការវះកាត់ថ្លើម (Liver Surgery) | ការវះកាត់ថ្លើមផ្នែកណាមួយចេញ (យ៉ាងហោចណាស់ មួយ(1)ក្លែប) ដែលជាតម្រូវការចាំបាច់ដោយសារតែជំងឺ ឬគ្រោះថ្នាក់នៃអ្នកត្រូវបានធានារ៉ាប់រង។<br><br>ការបរិច្ចាគថ្លើម និងជំងឺថ្លើមបណ្តាលមកពីការផឹកស្រា ឬការប្រើប្រាស់ថ្នាំលើសកម្រិតមិនត្រូវបានរាប់បញ្ចូលក្នុងការធានានេះទេ។ |
| 11 | សួត | ការវះកាត់យកសួតមួយចំហៀងទាំងមូលចេញ (Surgical Removal of One Lung) | ការវះកាត់យកសួតមួយចំហៀងទាំងមូលចេញដែលជាលទ្ធផលមកពីជំងឺ គ្រោះថ្នាក់នៃអ្នកត្រូវបានធានារ៉ាប់រង។<br><br>ការវះកាត់ផ្នែកខ្លះនៃសួតមិនត្រូវបានរាប់បញ្ចូលក្នុងការធានានេះទេ។ |
| 12 | តម្រងនោម | ការវះកាត់តម្រងនោមមួយចំហៀងចេញ (Nephrectomy / Removal of one Kidney) | ការវះកាត់តម្រងនោមមួយចំហៀងទាំងមូលចេញ ដែលជាលទ្ធផលមកពីជំងឺ ឬគ្រោះថ្នាក់នៃអ្នកត្រូវបានធានារ៉ាប់រង។ ការវះកាត់តម្រងនោមត្រូវតែបានបញ្ជាក់ថាចាំបាច់បំផុតដោយអ្នកជំនាញដែលពាក់ព័ន្ធ។<br><br>ការបរិច្ចាគតម្រងនោមមិនត្រូវបានរាប់បញ្ចូលក្នុងការធានានេះទេ។ |
| 13 | ការវះកាត់ផ្លាស់ប្តូរសរីរាង្គ | ការវះកាត់ផ្លាស់ប្តូរពោះវៀនតូច (Small Bowel Transplant) | ការវះកាត់ផ្លាស់ប្តូរពោះវៀនតូចយ៉ាងហោចណាស់មួយ (1) ម៉ែត្រ ជាមួយនឹងចរន្តឈាមចិញ្ចឹមផ្ទាល់ខ្លួន (with its own blood supply) តាមរយៈការវះកាត់បើកពោះ ដែលបណ្តាលមកពីការខូចពោះវៀនតូច។ |